ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ០៥៩-សណ-១៧ អអក

ភ្នំពេញ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់ក្រុមហ៊ុន លឹម ហេង គ្រុប សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅក្នុងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាបណ្ណរួម (ផលិតកម្ម និងចែកចាយ) ឲ្យក្រុមហ៊ុន លឹម ហេង គ្រុប សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ។ ពេលនេះ អាជ្ញាធរអគ្គិសនីកម្ពុជាបានអនុញ្ញាតឲ្យក្រុមហ៊ុន លឹម ហេង គ្រុប ទិញអគ្គិសនីពីអគ្គិសនីកម្ពុជា មកជំនួសឲ្យការផលិតដោយម៉ាស៊ីនផ្ទាល់ខ្លួន ។ ដោយឃើញថា នៅតំបន់ធ្វើសេវាកម្មអគ្គិសនីរបស់ក្រុមហ៊ុន លឹម ហេង គ្រុប លែងត្រូវការមធ្យោបាយផលិតកម្មទៀតហើយ ដូច្នេះ អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់ក្រុមហ៊ុន លឹម ហេង គ្រុប ដោយប្តូរប្រភេទអាជ្ញាបណ្ណ ពីអាជ្ញាបណ្ណរួមមកអាជ្ញាបណ្ណចែកចាយវិញ តាមខ្លឹមសារដូចមានជូនភ្ជាប់មកជាមួយនេះ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជា អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណ ដែលគ្រោងនឹងចេញនេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចនៅ......................................................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅក្នុងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យក្រុមហ៊ុន លឹម ហេង គ្រុប អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ។

អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា " **អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ** " ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ទី នរិន្ទ**

**សេចក្តីព្រាង**

# អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
ELECTRICITY LAW OF THE KINGDOM OF CAMBODIA

## សេចក្តីសម្រេចកែសម្រួលលើកទី១
## លើឯកសារអាជ្ញាបណ្ណលេខ ៣៧៤ ឯអ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ សម្រាប់ក្រុមហ៊ុន លីម ហេង គ្រុប ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ

## សម្រាប់ការប្តូរប្រភេទអាជ្ញាបណ្ណពីអាជ្ញាបណ្ណរួម មកអាជ្ញាបណ្ណចែកចាយ

**DECISION ON THE FIRST REVISION**

TO THE LICENSE DOCUMENT No.374 LD DATED NOVEMBER 26, 2013 OF LIM HENG GROUP CO., LTD FOR PROVIDING ELECTRIC POWER SERVICE AT SOME PART OF BANTEAY AMPIL DISTRICT, ODDOR MEANCHEY PROVINCE

**FOR CHANGING THE TYPE OF LICENSE**

**FROM CONSOLIDATED LICENSE TO DISTRIBUTION LICENSE**

ថ្ងៃទី ខែ ឆ្នាំ២០១៧

.. .., 2017